

# កម្មវិធី Medical Baseline

## ការសន្សប្រាក នងសវតភាពសម្រាបអតថជនដែលមានតម្រវការថាមពលបនែម

**កម្មវិធី Medical Baseline របស់ PG&E** គឺជាកម្មវិធីជំនួយសម្រាប់អតិថិជនរបស់ PG&E ដែលត្រូវការថាមពលសម្រាប់តម្រូវការវេជ្ជសាស្ត្រមួយចំនួន។

កម្មវិធីរួមមាន ដូចជា៖

- ការបែងចែកថាមពលប្រចាំខែបន្ថែមក្នុងអត្រាតម្លៃទាប
- ការជូនដំណឹងបន្ថែមសម្រាប់ការបិទថាមពលដើម្បីសុវត្ថិភាពសាធារណៈ (Public Safety Power Shutoffs -PSPS) *សូមមើលខាងក្រោយ* ▶▶

### ឧទាហរណ៍គំរូនៃស្ថានភាព និងឧបករណ៍វេជ្ជសាស្ត្រដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់៖

- ជំងឺហឺត/ការដកដង្ហើមមិនរួចនៅពេលគេង
- ប្រដាប់ជំនួយការដកដង្ហើម
- ការក្រិនច្រើនកន្លែង
- តម្រូវការប្រព័ន្ធកម្តៅ/ធ្វើឱ្យត្រជាក់ពិសេស
- រទេះរុញប្រើម៉ាស៊ីន
- ម៉ាស៊ីន IPPB/CPAP
- ម៉ាស៊ីនលាងឈាម



**ដាក់ពាក្យសចូលក្នុងកម្មវិធី MEDICAL BASELINE របស់ PG&E**
**សមចលទៅគេហទពរ PGE.COM/MEDICALBASELINE នៅថៃនេះ!**

**1 ពិនិត្យមើលលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបាន។**
ពិនិត្យឡើងវិញនូវបញ្ជីពេញលេញនៃស្ថានភាព និងឧបករណ៍វេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

**2 បំពេញទម្រង់ពាក្យសុំ។**
ចូលទៅគេហទំព័រ របស់យើងដើម្បីបំពេញទម្រង់ពាក្យសុំតាមអ៊ីនធឺណិត។

**3 ត្រូវឱ្យគ្រូពេទ្យរបស់អ្នកបំពេញទម្រង់ពាក្យសុំរបស់អ្នក។**
គ្រូពេទ្យដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ចាំបាច់ត្រូវបញ្ជាក់អំពីតម្រូវការថាមពលរបស់អ្នក។

អ្នកក៏អាចបោះពុម្ពច្បាប់ចម្លងនៃទម្រង់ពាក្យសុំដោយចូលទៅ
pge.com/medicalbaseline។

សូមផ្ញើពាក្យសុំដែលបានបំពេញរួចរបស់អ្នកទៅ៖

**PG&E Credit and Records Center**
**Medical Baseline**
P.O. Box 8329
Stockton, CA 95208

សម្រាប់សំណួរណាមួយ សូមទូរស័ព្ទមក៖
**1-800-743-5000**

## ការជូនដំណឹងបន្ថែមអំពី PSPS

ដើម្បីសុវត្ថិភាពសាធារណៈ យើងអាចនឹងត្រូវបិទថាមពលក្នុងអំឡុងពេលដែលមានអាកាសធាតុធ្ងន់ធ្ងរ ដើម្បីបង្ការភ្លើងឆេះព្រៃ។ នេះត្រូវបានគេស្គាល់ថាជា PSPS។

PG&E ផ្តល់ការជូនដំណឹងបន្ថែមដល់អតិថិជនរបស់ Medical Baseline មុនពេល និងអំឡុងពេលព្រឹត្តិការណ៍ PSPS។

យើងនឹងទូរស័ព្ទ ឬផ្ញើសារជាអក្សរទៅអ្នក។ **ទទួលទូរស័ព្ទ ហើយនិយាយ "សួស្តី" ឬឆ្លើយតបដោយលេខ "1" ទៅសាររបស់យើង** ដើម្បីប្រាប់យើងឱ្យដឹងថា អ្នកបានទទួលការជូនដំណឹងរបស់យើង។ ប្រសិនបើអ្នកមិនឆ្លើយតបទេ យើងនឹងព្យាយាមជូនដំណឹងទៅដល់អ្នកដោយផ្ទាល់។



## តើអ្នកអាចត្រៀមខ្លួនសម្រាប់ PSPS បានដោយរបៀបណា?

**ធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នក** និងចំណូលចិត្តភាសានៅគេហទំព័រ **pge.com/mywildfirealerts** ឬទូរស័ព្ទមកលេខ **1-866-743-6589**។

**ត្រៀមខ្លួន និងអនុវត្ត** ផែនការបន្ទាន់ និងពិនិត្យឡើងវិញនូវធនធានសុវត្ថិភាព។ **safetyactioncenter.pge.com**

**មើលថាតើ អ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬអត់ សម្រាប់ការទទួលបានអាគុយចល័តបម្រុងទុកដោយមិនគិតថ្លៃ** ដើម្បីផ្តល់ថាមពលដល់ឧបករណ៍វេជ្ជសាស្ត្រសំខាន់ៗ។ **pgebatteryprogram.com**

**ស្វែងរកការគាំទ្រ និងធនធាន** មុនពេល អំឡុងពេល និងក្រោយពេលព្រឹត្តិការណ៍ PSPS ។ **pge.com/pspssupport**

**ទទួលបានជំនួយបន្ថែម** ពីកម្មវិធីទទួលបាន និងផ្តល់ធនធានដល់ជនពិការ ពេលមានគ្រោះមហន្តរាយ។ **disabilitydisasteraccess.org**

**រុករកធនធានបន្ថែម** ដូចជាការដាក់ជំនួសអាហារ និងព័ត៌មានស្តីពីជំនួយហិរញ្ញវត្ថុ។ **pge.com/disabilityandaging**

**ត្រូវការជំនួយបន្ថែម ប៉ុន្តែមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី MEDICAL BASELINE ឬ?** ប្រសិនបើនរណាម្នាក់នៅក្នុងផ្ទះរបស់អ្នកមានស្ថានភាពធ្ងន់ធ្ងរដែលអាចក្លាយជាការគំរាមកំហែងដល់អាយុជីវិតដោយមិនមានថាមពល សូមបញ្ជាក់ដោយខ្លួនឯងសម្រាប់ស្ថានភាពអតិថិជនដែលងាយរងគ្រោះ។ ចូលទៅ **pge.com/vcstatus** ។

សម្រាប់ការគាំទ្រដែលបានបកប្រែជាភាសាបន្ថែមច្រើនជាង 250 ភាសា សូមទាក់ទង PG&E តាមលេខ **1-866-743-6589**។

វិធានការមួយចំនួនដែលមាននៅក្នុងឯកសារនេះត្រូវបានពិចារណាទុកជាវិធានការប្រុងប្រយ័ត្នទុកជាមុនបន្ថែម ដែលមានគោលបំណងកាត់បន្ថយបន្ថែមនូវហានិភ័យនៃភ្លើងឆេះព្រៃ។ "PG&E" សំដៅទៅលើក្រុមហ៊ុនហ្គាស និងអគ្គិសនីប៉ាស៊ីហ្វិក ដែលជាបុត្រសម្ព័ន្ធរបស់សាជីវកម្ម PG&E ។ ©2021 ក្រុមហ៊ុនហ្គាស និងអគ្គិសនីប៉ាស៊ីហ្វិក។ រក្សាសិទ្ធិគ្រប់យ៉ាង។ CCC-0521-3521។ 06/14/2021.